**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា** | **គណៈកម្មការមូលបត្រកម្ពុជា** | **អគ្គស្នងការដ្ឋាននគរបាលជាតិ**

# សេចក្តីថ្លែងការណ៍រួម
# របស់
# ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិ

នាពេលថ្មីៗកន្លងមកនេះ អាជ្ញាធរមានសមត្ថកិច្ចបានសង្កេតឃើញថា មានការផ្សព្វផ្សាយ ចរាចរ ទិញ លក់ ជួញដូរ ទូទាត់ កាសអេឡិចត្រូនិក ដូចជា KH Coin, Suncoin, K coin, One-coin, Forex coin និងកាសអេឡិចត្រូនិកប្រហាក់ប្រហែលយ៉ាងសកម្មនៅក្នុងប្រទេសកម្ពុជា។

អាជ្ញាធរមានសមត្ថកិច្ចសូមបញ្ជាក់ថា ការផ្សព្វផ្សាយ ចរាចរ ទិញ លក់ ជួញដូរ ទូទាត់ កាសអេឡិចត្រូនិកដោយមិនមានអាជ្ញាប័ណ្ណពីអាជ្ញាធរមានសមត្ថកិច្ចគឺជាសកម្មភាពខុសច្បាប់។

ការផ្សព្វផ្សាយ ចរាចរ ទិញ លក់ ជួញដូរ ទូទាត់កាសអេឡិចត្រូនិកដូចជា KH Coin, Suncoin, K coin, One-coin, Forex coin និងកាសអេឡិចត្រូនិកប្រហាក់ប្រហែលដែលមិនមានការគ្រប់គ្រងពីអាជ្ញាធរមានសមត្ថកិច្ច នឹងបង្កហានិភ័យធ្ងន់ធ្ងរដល់សាធារណជន និងសង្គមទាំងមូលដូចជា៖

- ចេញផ្សាយដោយពុំមានវត្ថុធានាសងត្រលប់មកវិញនោះឡើយ
- ទទួលរងការខាតបង់លើការវិនិយោគ ដោយសារតែតម្លៃចារីករបស់កាសអេឡិចត្រូនិកប្រែប្រួលគ្មានមូលដ្ឋានច្បាស់លាស់

- ប្រឈមនឹងឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងធ្វើឱ្យបាត់បង់មូលនិធិ ដោយសារការលួចចូលទៅក្នុងប្រព័ន្ធ
- ពុំមានយន្តការការពារផលប្រយោជន៍អតិថិជន អ្នកប្រើប្រាស់កាសអេឡិចត្រូនិក ជាជនអនាមិក ពុំមានការសម្គាល់អត្តសញ្ញាណ ឬ សាវតារបស់អ្នកប្រើប្រាស់បានច្បាស់លាស់ គឺជាហានិភ័យក្នុងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ដូច្នេះស្ថិតក្នុងដំណាក់កាលនេះ អាជ្ញាធរមានសមត្ថកិច្ចសូមអំពាវនាវដល់សាធារណជនទាំងអស់មេត្តាប្រុងប្រយ័ត្ន ចំពោះការឃោសនាផ្សព្វផ្សាយកៀរគរប្រមូលមូលនិធិ និងធ្វើប្រតិបត្តិការ ទិញ លក់ ដូរ ទូទាត់ កាសអេឡិចត្រូនិកដែលមិនមានអាជ្ញាប័ណ្ណពីអាជ្ញាធរមានសមត្ថកិច្ច។

បុគ្គល ឬ នីតិបុគ្គលណាដែលធ្វើការឃោសនាផ្សព្វផ្សាយ កៀរគរប្រមូលមូលនិធិ ធ្វើប្រតិបត្តិការ ទិញ លក់ ដូរ ទូទាត់កាសអេឡិចត្រូនិកដោយមិនមានអាជ្ញាប័ណ្ណពីអាជ្ញាធរមានសមត្ថកិច្ច នឹងត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់ជាធរមាន។

អាជ្ញាធរមានសមត្ថកិច្ចសង្ឃឹមថា សាធារណជនទាំងអស់នឹងយកស្មារតីរបស់សេចក្តីថ្លែងការណ៍នេះទៅអនុវត្តឱ្យបានយ៉ាងខ្ជាប់ខ្ជួន។

ថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៨